**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2012, 12:17
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យប្រភេទនៃចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារ ក្នុងពេលផ្ដល់សក្ខីកម្មរបស់សាក្សី**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្ដារា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្ដម
លោក Michael G.KARNAVAS
លោក គង់ សំអុន

លោក Arthur VERCKEN
លោកស្រី Anta GUISSE
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាដាក់ជូនសំណើដូចខាងក្រោមនេះ ទាក់ទងនឹងការប្រើប្រាស់ឯកសារនៅក្នុងអម្លុងពេលផ្តល់សក្ខីកម្មរបស់សាក្សីក្នុងពេលសវនាការ។ តាមការសម្រេចផ្ទាល់មាត់របស់ខ្លួន នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានសម្រេចថា បើសិនសាក្សីណាម្នាក់មិនបានដឹងអំពីឯកសារណាមួយ មិនអាចផ្តល់អត្តសញ្ញាណចំពោះឯកសារណាមួយ ឬមិនធ្លាប់បានឃើញឯកសារណាមួយពីមុន ឯកសារនោះគួរតែដកចេញពីសាក្សីរូបនោះ និងមិនត្រូវដាក់បង្ហាញនៅលើអេក្រង់ឡើយ[1]។ អង្គជំនុំជម្រះបានសម្រេចបន្ថែមទៀតថា ទោះបីឯកសារមិនឃើញ ឬមិនបានបង្ហាញជូនសាក្សីក៏ដោយ ក៏ភាគីនៅតែអាចតាំងសំណួរផ្សេងៗទៅកាន់សាក្សីទាក់ទងនឹងបញ្ហាប្រធានបទនៃឯកសារនោះបាន[2]។ តាំងពីមានការសម្រេចដូច្នេះមក អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការកែសម្រួល ឬការលើកលែងមួយចំនួនចំពោះវិធានទូទៅនេះ[3]។

២- សហព្រះរាជអាជ្ញារំពឹងទៅលើឯកសារសវនាការមួយចំនួនចំពោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនាពេលខាងមុខ ដែលនឹងមកផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/១។ ការដាក់សេចក្តីសន្និដ្ឋាននេះ បញ្ជាក់ឲ្យឃើញអំពីការរំពឹងទុករបស់សហព្រះរាជអាជ្ញាក្នុងការប្រើប្រាស់ឯកសារសវនាការ ដើម្បីផ្តល់ជូនជាមុននូវការជូនដំណឹងដល់អង្គជំនុំជម្រះ និងគូភាគីអំពីយុត្តិកម្មនៃគោលជំហររបស់សហព្រះរាជអាជ្ញា ដោយមានការពិចារណាយ៉ាងយកចិត្តទុកដាក់អំពីសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះ។ មានឯកសារយោងទៅនឹងវិធាននីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ និងចំពោះការបង្ហាញគោលបំណង មានឯកសារយោងទៅនឹងទម្លាប់នៃការអនុវត្តនៃប្រព័ន្ធច្បាប់ក្នុងស្រុកផងដែរ។ គោលបំណងនៃការដាក់សេចក្តីសន្និដ្ឋាននេះ គឺដើម្បីជៀសវាងយ៉ាងណាកុំឲ្យមានការពន្យារពេល និងអាក់ខានផ្សេងៗ នៅក្នុងអម្លុពេលផ្តល់សក្ខីកម្មរបស់សាក្សីតាមរយៈការស្វែងរកការបំភ្លឺពីអង្គជំនុំជម្រះជាមុន អំពីគោលបំណងនានាដែលអាចអនុញ្ញាតបានសម្រាប់សាក្សីណាដែលអាចបង្ហាញឯកសារជូន នៅក្នុងរយៈពេលនៃដំណើរការនៃការផ្តល់សក្ខីកម្មរបស់សាក្សី។

---

[1] **E1/52.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២១ មីនា ២០១២ (ថ្ងៃសវនាការទី៤០), ត្រង់ទំព័រ៦២, ៦៧។

[2] **E1/52.1** *ដដែលដូចខាងលើ,* ត្រង់ទំព័រ៦៧។

[3] **E1/56.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៩ មីនា ២០១២ (ថ្ងៃសវនាការទី៤៤), ទំព័រ៧២-៧៥។ **E1/68.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៥ មេសា ២០១២ (ថ្ងៃសវនាការទី៥៦), ទំព័រ១-៣, ៨-៩។ **E1/73.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ១៧ ឧសភា ២០១២ (ថ្ងៃសវនាការទី៦១), ទំព័រ៦៧-៧០, ៧២-៧៦។

៣- សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដោយអនុវត្តតាមវិធាននីតិវិធី និងការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ ភស្តុតាងជាឯកសារអាចបង្ហាញយ៉ាងត្រឹមត្រូវនៅក្នុងរយៈពេលនៃដំណើរការផ្តល់សក្ខីកម្មរបស់សាក្សី ដើម្បីបំពេញយ៉ាងហោចណាស់នូវគោលបំណងបួនៈ (១) **ដើម្បីរំលឹកការចងចាំ**របស់សាក្សី (២) ដើម្បីកំណត់**យថាភូត**ចំពោះឯកសារណាមួយ*តាមរយៈការសន្ទូតមួយក្រឡេកម្ដែក* ឬដើម្បីជួយអង្គជំនុំជម្រះក្នុងការវាយតម្លៃអំពី**ទម្ងន់**នៃភស្តុតាង ដែលចុងក្រោយនឹងត្រូវយកចេញពីឯកសារនោះ (៣) ដើម្បី**ធ្វើបមាណីកម្មបញ្ជាក់**ទៅលើសារធាតុ ឬធ្វើជាការសង្ខេបចេញពីខ្លឹមសារនៃឯកសារនោះ ដោយផ្អែកលើចំណេះដឹងដោយផ្ទាល់របស់សាក្សីរូបនោះ និង(៤)ដើម្បីសាកល្បងនូវ**ភាពជឿជាក់**ចំពោះសាក្សី។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការប្រើប្រាស់នូវភស្តុតាងឯកសារដូច្នេះជារឿងចាំបាច់ និងសមស្រប នៅក្នុងបរិបទនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដ៏ស្មុគស្មាញ ដើម្បីវាយតម្លៃពីសច្ចសីលភាពនៃអង្គហេតុទាំងឡាយ ដែលកើតឡើងបីទសវត្សរ៍កន្លងមកហើយ។ អភិក្រមដែលបានស្នើឡើងនេះ ក៏ឆ្លុះបញ្ចាំងឲ្យឃើញអំពីចេតនានៃការសម្រេចផ្ទាល់មាត់ពីមុនៗរបស់អង្គជំនុំជម្រះផងដែរ ក្នុងកាលៈទេសៈដែលសាក្សីម្នាក់ត្រូវបានរកឃើញថាមានចំណេះដឹងគ្រប់គ្រាន់ចំពោះឯកសារណាមួយ ដើម្បីអនុញ្ញាតយកមកប្រើប្រាស់ ក្នុងរយៈពេលនៃដំណើរការផ្តល់សក្ខីកម្ម។ សេចក្តីសម្រេចទាំងនេះមានចែងដូចខាងក្រោម។

៤- សហព្រះរាជអាជ្ញារំពឹងទុកថា សំណើសុំទាក់ទងនឹងការប្រើប្រាស់ភស្តុតាងឯកសារជាមួយនឹងសាក្សីនឹងកើតឡើងនៅក្នុងរយៈពេលនៃដំណើរការផ្តល់សក្ខីកម្ម ដែលបានកំណត់ពេលរួចហើយក្នុងសំណុំរឿង០០២/១ ព្រមទាំងក្នុងដំណាក់កាលក្រោយៗទៀតនៃកិច្ចដំណើរការនីតិវិធី។ ជាពិសេស សហព្រះរាជអាជ្ញារំពឹងទុកអំពីការបង្ហាញជូនសាក្សីនាពេលអនាគត នូវឯកសារផ្សេងៗ ដែលមានទំនាក់ទំនងគ្រប់គ្រាន់ទៅនឹងចំណេះដឹងដោយផ្ទាល់របស់សាក្សី ប៉ុន្តែមិនចាំបាច់ថាឯកសារនោះត្រូវបាននិពន្ធដោយពួកគាត់ដោយផ្ទាល់នោះទេ ដូចជាសារទូរលេខ កំណត់ហេតុនៃអង្គប្រជុំ ការបោះពុម្ពផ្សាយរបាយការណ៍ និងប្រតិចារិកនៃបទឧទ្ទេសនាមផ្សេងៗ។

## II. ប្រវត្តិនីតិវិធី

៥- នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ នៅក្នុងចម្លើយតបទៅនឹងការជំទាស់ធ្វើឡើងដោយមេធាវីការពារក្តី នៅក្នុងពេលផ្តល់សក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច អង្គជំនុំជម្រះបានសម្រេចថា បើសិនជាសាក្សី "មិនបានដឹងអំពីឯកសារ" និង "មិនអាចកំណត់អត្តសញ្ញាណឯកសារនោះបាន ឬក៏ថាគាត់មិនធ្លាប់ឃើញឯកសារនោះពីមុនមក ឯកសារនោះត្រូវតែដកចេញពីគាត់ និងចេញពីអេក្រង់នៅពីមុខគាត់"[4]។ អង្គជំនុំជម្រះបានបន្ថែមថា ទោះបីជាឯកសារជាក់លាក់ណាមួយមិនអាចបង្ហាញ ឬដកស្រង់ជូនសាក្សីក៏ដោយ ក៏ភាគី "អាចតាំងសំណួរផ្សេងៗបាន ដោយផ្អែកទៅលើប្រធានបទនៅក្នុងឯកសារនោះ"[5]។

៦- នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ សហមេធាវីការពារក្តី ខៀវ សំផន ដោយផ្អែកលើការសម្រេចនេះ បានជំទាស់ទៅនឹងកំណត់ហេតុសួរចម្លើយមួយនៅមន្ទីរស-២១ ដែលសហព្រះរាជអាជ្ញាចង់បង្ហាញជូនសាក្សី ឌុច។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចំពោះការជំទាស់នោះ ដោយសម្រេចថា ទោះបីជា ឌុច មិនអាចនឹកឃើញថាគាត់បានឃើញឯកសារជាក់លាក់នោះពីមុនមកក៏ដោយ ក៏គាត់បានស្គាល់យ៉ាងគ្រប់គ្រាន់ ឬដឹងអំពីប្រភេទជាទូទៅ ឬក្រុមនៃឯកសារ (ដែលជាទម្រង់បទដ្ឋាននៃកំណត់ហេតុមួយដែលគេបានប្រើប្រាស់នៅមន្ទីរស-២១ ទាក់ទងនឹងការសួរចម្លើយអ្នកទោស) ថាជាការសមស្រប ដើម្បីបង្ហាញជូនគាត់នូវឯកសារនោះ និងឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធ នៅក្នុងរយៈពេលនៃដំណើរការនៃការផ្តល់សក្ខីកម្មរបស់គាត់[6]។

៧- នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ នៅក្នុងពេលនៃការផ្តល់សក្ខីកម្មរបស់ ពាន ឃាន អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យមេធាវីការពារក្តី នួន ជា បង្ហាញជូនសាក្សីនូវសេចក្តីសង្ខេបពីរនៃបទសម្ភាសន៍របស់សាក្សីផ្សេងទៀត (សេចក្តីសង្ខេបមួយក្នុងចំណោមសេចក្តីសង្ខេបទាំងពីរនៃបទសម្ភាសន៍នោះ មាននៅក្នុងរបាយការណ៍មួយស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស)។ សាក្សីទាំងនេះមិនត្រូវបានកំណត់ពេលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទេ។ អង្គជំនុំជម្រះបានសម្រេចពីដំបូងថា "គេមិនអាចប្រើឯកសារណាដែលជាកំណត់ហេតុរបស់សាក្សីដែលនឹងត្រូវស្តាប់

[4] **E1/52.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២១ មីនា ២០១២ (ថ្ងៃសវនាការទី៤០), ត្រង់ទំព័រ៦២, ៦៧ ("បើសាក្សីមិនស្គាល់ឯកសារ នោះត្រូវយកឯកសារនោះចេញពីគាត់")។

[5] **E1/52.1** *ដដែលដូចខាងលើ,* ត្រង់ទំព័រ៦៧។

[6] **E1/56.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២៩ មីនា ២០១២ (ថ្ងៃសវនាការទី៤៤), ទំព័រ៧២-៧៥ (ការប្រើប្រាស់កំណត់ហេតុមន្ទីរស-២១, ឯកសារ D108/26.282)។

ចម្លើយនៅដំណាក់កាលក្រោយៗទៀតឡើយ"[7] និងសម្រេចលើកទីពីរថា បើ ពាន ឃាន "មិនស្គាល់សាក្សីដែលបានផ្តល់កំណត់ហេតុ ឬប្រធានបទនោះមិនស្ថិតក្នុងក្របខ័ណ្ឌនៃការដេញដោល នោះអង្គចៅក្រមគ្រាន់តែសម្រេចថា ការសួរសំណួរនឹងមិនត្រូវបន្តធ្វើទៀតទេ"[8]។

## III. អំណះអំណាង

*តម្រូវការចាំបាច់ឲ្យមានទំនាក់ទំនងគ្រប់គ្រាន់រវាងឯកសារ និងចំណេះដឹងដោយផ្ទាល់របស់សាក្សី*

៨- សេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការប្រើប្រាស់ដែលអាចអនុញ្ញាតបានចំពោះឯកសារសវនាការជាមួយនឹងសាក្សី បានផ្តោតទៅលើថាតើសាក្សីបានស្គាល់ឯកសារ ឬមានចំណេះដឹងផ្ទាល់ខ្លួនដែលនឹងអនុញ្ញាតឲ្យគាត់ពិនិត្យមើល និងផ្តល់សក្ខីកម្មបានអំពីឯកសារនោះដែរ ឬអត់។ សហព្រះរាជអាជ្ញាស្វែងរកការគាំទ្រពីសំណាក់ករណីយុត្តិសាស្ត្ររបស់បណ្តាតុលាការ *ពិសេស* នានា ដើម្បីជាអភិក្រមប្រកបដោយគោលការណ៍ ដែលពិនិត្យលើភាពគ្រប់គ្រាន់នៃទំនាក់ទំនងរវាងសាក្សី និងឯកសារ និងថាតើសាក្សីមានចំណេះដឹងចាំបាច់ដើម្បីផ្តល់សក្ខីកម្មពីឯកសារនោះដែរ ឬអត់ ដោយពុំគិតថាសាក្សីអាចនឹកឃើញអំពីការបានឃើញឯកសារនោះពីមុនមកឡើយ។

៩- ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY បានកំណត់ថា សាក្សីអាចផ្តល់សក្ខីកម្មអំពីទិដ្ឋភាពនៃខ្លឹមសារនៃឯកសារដែលសាក្សីមិនធ្លាប់បានឃើញពីមុន ជាគោលបំណងដើម្បីងាយយល់លើប្រភពដើម និង/ឬខ្លឹមសាររបស់ឯកសារ ហេតុដូចនេះ វានឹងជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃឲ្យបានត្រឹមត្រូវអំពីយថាភូត ភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាននៃឯកសារ និងជាចុងក្រោយ គឺសម្រាប់ការប្រើប្រាស់ឯកសារប្រកបអត្ថន័យ ក្នុងការពិចារណាជារួមទៅលើភ័ស្តុតាងក្នុងករណីនោះ[9]។ សាក្សីមិនគួរអនុញ្ញាតឲ្យពិនិត្យ ឬផ្តល់សក្ខីកម្មអំពីឯកសារណាមួយដែលឯកសារនោះសាក្សី "មិនដឹង ឬមិនអាចនិយាយបាន" អំពីប្រធានបទនៃឯកសារនោះ ឬមួយសាក្សី "មិនស្ថិតក្នុងគោលជំហរនិយាយ

---

[7] **E1/73.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ១៧ ឧសភា ២០១២ (ថ្ងៃសវនាការទី៦១), ត្រង់ទំព័រ៧៦។

[8] **E1/73.1** *ដដែលដូចខាងលើ,* ត្រង់ទំព័រ៧៦។

[9] *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić*, សេចក្តីសម្រេចអំពីគោលការណ៍ណែនាំសម្រាប់ការទទួលយកជាភ័ស្តុតាងតាមរយៈសាក្សី IT-95-5118-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ១៩ ឧសភា ២០១០ ត្រង់កថាខណ្ឌទី១១។

ពីអ្វីមួយឲ្យមានអត្ថន័យអំពីឯកសារនោះឡើយ”[10]។ ក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ការពិចារណាជាមូលដ្ឋាន គឺថាតើមានទំនាក់ទំនងគ្រប់គ្រាន់រវាងសាក្សី និងឯកសារដែរ ឬទេ ដើម្បីជាយុត្តិកម្មក្នុងការដាក់ឯកសារនោះជូនសាក្សី[11]។

១០- ឲ្យតែមានទំនាក់ទំនងគ្រប់គ្រាន់រវាងប្រភពដើម ទម្រង់ លក្ខណៈ ឬខ្លឹមសារនៃឯកសារ និងចំណេះដឹងផ្ទាល់របស់សាក្សី នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា វាជាការសមស្របដើម្បីបង្ហាញឯកសារនោះជូនសាក្សី។ តាមពិត ការណ៍នេះគួរតែបានធ្វើ ដើម្បីកុំឲ្យមានការដឹកនាំសាក្សីដោយមិនត្រឹមត្រូវ ឬធ្វើឲ្យចំណេះដឹងរបស់សាក្សីប្រឡូកប្រឡាក់ជាមួយនឹងព័ត៌មាននៅក្នុងឯកសារនោះ។

១១- អនុលោមតាមការសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង និងតុលាការអន្តរជាតិដទៃទៀត សហព្រះរាជអាជ្ញារំពឹងទុកថា នឹងប្រើប្រាស់ឯកសារសវនាការជាមួយនឹងសាក្សីពេលអនាគត យ៉ាងហោចណាស់សម្រាប់គោលបំណងបួនជាក់លាក់:(១) ដើម្បី**រំលឹកការចងចាំ**របស់សាក្សី (២) ដើម្បីកំណត់**យថាភូត**ចំពោះឯកសារណាមួយ*តាមរយៈការសួរតមួយក្រឡេកដ៏ឆ្លុក* ឬដើម្បីជួយអង្គជំនុំជម្រះក្នុងការវាយតម្លៃអំពី**ទម្ងន់** ដែលចុងក្រោយនឹងត្រូវយកមកពីឯកសារនោះ (៣) ដើម្បី**ធ្វើបមាណីកម្មបញ្ជាក់**ទៅលើសារធាតុ ឬសង្ខេបចេញពីខ្លឹមសារនៃឯកសារនោះ ដោយផ្អែកលើចំណេះដឹងដោយផ្ទាល់របស់សាក្សីរូបនោះ និង(៤)ដើម្បីសាកល្បងនូវ**ភាពជឿជាក់**ចំពោះសាក្សី។ ការប្រើប្រាស់ឯកសារនិមួយៗដូចបានរំពឹងទុកនេះ ត្រូវបានធ្វើយុត្តិកម្មដូចខាងក្រោម ដោយមានសេចក្តីយោងទៅលើវិធាននីតិវិធីដែលបានកំណត់នៅថ្នាក់អន្តរជាតិ ដែលអង្គជំនុំជម្រះអាចយោងបាន ស្របតាមមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក រួមទាំងឧទាហរណ៍ចង្អុលបង្ហាញអំពីប្រព័ន្ធច្បាប់ជាតិ។

## *ការរំលឹកដល់ការចងចាំរបស់សាក្សី*

[10] *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić*, IT-95-5118, ប្រតិចារិក, ៦ ឧសភា ២០១០ ត្រង់កថាខណ្ឌទី១៩៥២។ *រដ្ឋអាជ្ញា ទល់នឹង Slobodan Milosević*, IT-02-54-T, សេចក្តីសម្រេចលើញត្តិរបស់អយ្យការសុំឲ្យពិចារណាឡើងវិញអំពីភ័ស្តុតាងរបស់សាក្សីខាងមេធាវីការពារក្តីឈ្មោះ Mitar Balevic,Vladislav Jovanovic, Vukasin Andric, និង Dobre Aleksovski និងសេចក្តីសម្រេច*តាមឆន្ទានុសិទ្ធិរបស់ខ្លួនផ្ទាល់* អំពីការពិចារណាឡើងវិញចំពោះការទទួលយកវត្ថុតាងលេខ ៨៣៧ និង៨៣៨ ទាក់ទងនឹងភ័ស្តុតាងរបស់សាក្សីខាងមេធាវីការពារក្តីឈ្មោះ Barry Lituchy, ១៨ ឧសភា ២០០៥ ត្រង់កថាខណ្ឌទី៩។

[11] *ដដែលដូចខាងលើ*។

១២- ករណីយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICC បានកំណត់យ៉ាងច្បាស់ថា បើសាក្សីបង្ហាញឱ្យឃើញថា មានការលំបាកក្នុងការរំលឹកឡើងវិញអំពីមនុស្ស ទីកន្លែង ឬព្រឹត្តិការណ៍ជាក់លាក់ណាមួយ អាចបង្ហាញបានដោយឯកសារផ្សេងៗដែលគេបានធ្វើ អនុម័ត ឬយោងពីមុនដោយពួកគាត់ ដើម្បីជាការរំលឹកដល់ការចងចាំរបស់ពួកគាត់។ ជាទាហរណ៍ ក្នុងករណី *Lubanga Dyilo* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC បានអនុញ្ញាតឱ្យសាក្សីម្នាក់នាំយកមកកាន់ទីកន្លែងសម្រាប់សាក្សីអង្គុយនូវកំណត់ហេតុដែលគាត់បានធ្វើ និងឯកសារដទៃផ្សេងទៀតដែលបានរៀបចំដោយខ្លួនគាត់ផ្ទាល់ដែលនឹងជួយដល់ការរំលឹកដល់ការចងចាំរបស់គាត់ ដោយសារការកន្លងផុតទៅនៃពេលវេលារវាងព្រឹត្តិការណ៍នោះ និងកិច្ចដំណើរការនីតិវិធីសវនាការ - ដែលជាបញ្ហាមួយមានរយៈពេលច្រើនឆ្នាំមកហើយ[12]។ អង្គជំនុំជម្រះគ្រាន់តែតម្រូវថា សាក្សីត្រូវជូនដំណឹងដល់អង្គជំនុំជម្រះនៅពេលណាគាត់គិតថាគាត់ត្រូវការយោងទៅលើឯកសារនោះ[13]។ អង្គជំនុំជម្រះបានកត់សម្គាល់ពីមុនថាកំណត់ហេតុសាក្សីដែលមានចុះហត្ថលេខា ឬបទសម្ភាសន៍ថតជាខ្សែអាត់សម្លេងដែលគេទាញយកកំណត់ហេតុនោះ ទាំងពីរគឺជាមធ្យោបាយសមស្របដែលសាក្សីអាចរំលឹកឡើងវិញអំពីការចងចាំរបស់ខ្លួន[14]។ ក្នុងករណី *Hadžihasanović* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានរកឃើញថា កំណត់ហេតុពីមុនដែលបានប្រើដើម្បីរំលឹកដល់ការចងចាំ មិនចាំបាច់យកជាភស្តុតាងអ្វីទាំងអស់[15]។ កាលណាការចងចាំរបស់សាក្សីត្រូវបានរំលឹកឡើងវិញ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាពីមធ្យោបាយ និងកាលៈទេសៈផ្សេងៗដែលនាំឱ្យការចងចាំនោះកើតឡើងវិញ នៅពេលធ្វើការវាយតម្លៃអំពីភាពជឿទុកចិត្តបាន និងសុចរិតភាពចំពោះសក្ខីកម្មរបស់សាក្សី[16]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏អនុញ្ញាតឱ្យមានការរំលឹកដល់ការចងចាំ តាមរយៈការសួរសាក្សីរបស់ភាគីបដិបក្ខ និងការសួរសាក្សីផ្ទាល់ខ្លួន[17]។

---

[12] *រដ្ឋអាជ្ញា ទល់នឹង* Thomas Lubanga Dyilo, សំណុំរឿងលេខ: ICC-01/04-01/06, ប្រតិចារិក, ៧ កក្កដា ២០០៩ ត្រង់ទំព័រទី៧។

[13] *ដដែលដូចខាងលើ*។

[14] *រដ្ឋអាជ្ញា ទល់នឹង* Thomas Lubanga Dyilo, សំណុំរឿងលេខ: ICC-01/04-01/06, ប្រតិចារិក, ១៦ មករា ២០០៩ ត្រង់ទំព័រទី១៦-២៩។

[15] *រដ្ឋអាជ្ញា ទល់នឹង* Blagoje Simić នឹងគូកន., សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំអំពីការប្រើប្រាស់កំណត់ហេតុផ្សេងៗដែលមិនបានទទួលយកជាភស្តុតាង អនុលោមតាមវិធាន៩២*ស្ទួន* ធ្វើជាមូលដ្ឋានដើម្បីតវ៉ាលើភាពជឿជាក់ និងដើម្បីរំលឹកដល់ការចងចាំ, សំណុំរឿងលេខ: IT-95-9-AR73.6 & IT-95-9-AR73.7. អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ២៣ ឧសភា ២០០៣, ត្រង់កថាខណ្ឌទី១៦, ១៨។

[16] *រដ្ឋអាជ្ញា ទល់នឹង Enver Hadžihasanović និង Amir Kubura*, សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំទាក់ទងនឹងការរំលឹកដល់ការចងចាំរបស់សាក្សី, សំណុំរឿងលេខ: IT-01-47-AR73.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ២ មេសា ២០០៤, ត្រង់ទំព័រទី៣។

[17] *រដ្ឋអាជ្ញា ទល់នឹង Enver Hadžihasanović និង Amir Kubura*, *ដដែលដូចខាងលើ*។ សូមអានផងដែរ *រដ្ឋអាជ្ញា ទល់នឹង* Blagoje Simić នឹងគូកន., សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំអំពីការប្រើប្រាស់កំណត់ហេតុផ្សេងៗដែលមិនបានទទួលយកជាភស្តុតាង អនុលោម

១៣- ការប្រើប្រាស់ឯកសារផ្សេងៗដើម្បីរំលឹកការចងចាំឡើងវិញនៅក្នុងពេលធ្វើសក្ខីកម្ម ត្រូវបានគេបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកក្នុងទំនៀមទំលាប់របស់ប្រព័ន្ធច្បាប់ខំម៉ុនឡ។ នៅក្នុងករណីរឿងក្តីកាលពីដើមដំបូងរបស់ *Henry ទល់នឹង Lee* នៅក្នុងយុត្តាធិការរបស់ប្រទេសអង់គ្លេស និង Wales, តុលាការយុត្តិធម៌នៃ Ellenborough LCJ បានរកឃើញថា សាក្សីមិនចាំបាច់ជាអ្នកផលិតដោយខ្លួនឯងដោយផ្ទាល់នូវឯកសារដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីសាក្សីរំលឹកការចងចាំរបស់ខ្លួនឡើងវិញនោះទេ៖

> *បើសិន នៅពេលពិនិត្យមើលឯកសារណាមួយ មកទល់ពេលនេះគាត់អាចរំលឹកនូវការចងចាំរបស់គាត់ឡើងវិញបានដូចជាធ្វើឱ្យគាត់នឹកឃើញអំពីកាលៈទេសៈណាមួយនោះគឺវាគ្រប់គ្រាន់ហើយ ហើយគ្មានអ្វីខុសប្លែកពីគ្នានោះទេដែលថា អនុស្សរណៈនេះមិនមែនសរសេរដោយខ្លួនគាត់ផ្ទាល់ ព្រោះវាមិនមែនជាអនុស្សរណៈដែលជាភស្តុតាង នោះទេ តែវាគ្រាន់តែជាការនឹកឃើញឡើងវិញរបស់សាក្សីប៉ុណ្ណោះ*[18] ។

១៤- *នៅក្នុងករណីរឿងក្តីរបស់ R ទល់នឹង Singh* [19] មន្ត្រីនគរបាលពីរនាក់បានសន្ទនាជាមួយនឹងជនជាប់ចោទ។ មន្ត្រីម្នាក់បានធ្វើកំណត់ហេតុអំពីការសន្ទនានោះ ហើយកំណត់ហេតុទាំងនេះត្រូវបានពិនិត្យមើលឡើងវិញដោយមន្ត្រីនគរបាលម្នាក់ទៀតប្រហែលជា១៨ម៉ោងក្រោយមក ដែលក្នុងពេលនោះមន្ត្រីនគរបាលដែលពិនិត្យឡើងវិញនោះបានសារភាពថា គាត់អាចនឹកឃើញឡើងវិញបានតែពីផលប៉ះពាល់ជាទូទៅនៃការសន្ទនានោះតែប៉ុណ្ណោះ តែមិនចាំអំពីពាក្យសំដីដែលបាននិយាយនោះទេ។ ខាងអយ្យការខំប្រឹងរកវិធីយ៉ាងណា ដើម្បីធ្វើឲ្យមន្ត្រីនោះរំលឹកការចងចាំរបស់ខ្លួនឡើងវិញតាមរយៈកំណត់ហេតុ

---

តាមវិធាន៩២*ស្ទួន* ធ្វើជាមូលដ្ឋានដើម្បីតវ៉ាលើភាពជឿជាក់ និងដើម្បីរំលឹកដល់ការចងចាំ, សំណុំរឿងលេខៈ IT-95-9-AR73.6 & IT-95-9-AR73.7. អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ២៣ ឧសភា ២០០៣, ត្រង់កថាខណ្ឌទី១៨។

[18] (1814), 2 Chitty 124, បានលើកជាសំអាងដោយមានការយល់ព្រម នៅក្នុងករណីរឿងក្តីរបស់ *R ទល់នឹង B (KG)* 1998 CanLII 7125 (សាលាឧទ្ធរណ៍នៃតុលាការទីក្រុង Ontario, ប្រទេសកាណាដា) ត្រង់កថាខណ្ឌទី១៨។ ស្ថានភាពនៃប្រព័ន្ធច្បាប់ខំមុនឡ នៅក្នុងប្រទេសអង់គ្លេស និងវេល ត្រូវបានអភិវឌ្ឍន៍ថែមទៀត នឹងធ្វើឱ្យទៅជាក្រមនៅក្នុង S. 139 នៅក្នុងច្បាប់ស្តីពីប្រព័ន្ធយុត្តិធម៌ ឆ្នាំ២០០៣ ដែលបានចែងថាការចងចាំរបស់សាក្សីអាចត្រូវបានឱ្យធ្វើការរំឭកឡើងវិញបាន “តាមរយៈឯកសារ ដែលត្រូវបានធ្វើឡើង ឬផ្ទៀងផ្ទាត់ដោយគាត់កាលពីពេលមុននេះ...”

[19] សំណុំរឿងលេខ [1976] 15 SASR 591 (លើកជាសំអាងដោយមានការយល់ព្រមតុលាការកំពូលនៃរដ្ឋ South Australia)។

នោះ នៅក្នុងសវនាការ។ ក្នុងខណៈពេលនោះ តុលាការបានរកឃើញថា មន្ត្រីនោះមានការចងចាំខ្សោយអំពីព្រឹត្តិការណ៍កាលពីពេលនោះ ដែលធ្វើឱ្យគាត់មិនអាចមានលទ្ធភាពធ្វើការបែងចែកដាច់ស្រឡះពីគ្នាបានរវាងការនឹកឃើញឡើងវិញរបស់គាត់ផ្ទាល់ ពីអ្វីដែលចុះនៅក្នុងកំណត់ហេតុដែលគាត់បានអានក្នុងពេល១៨ម៉ោងក្រោយមកទៀតនោះបានទេ ហើយមន្ត្រីរូបនោះបានបដិសេធលើសំណើសុំចោទប្រកាន់របស់អយ្យការ។ ក៏ប៉ុន្តែតុលាការបានសម្រេចថា បើសិនសាក្សីស្ថិតនៅក្នុងស្ថានភាពមួយថា ខ្លួននឹងអាចបែងចែកដាច់ពីគ្នាបាន រវាងការនឹកឃើញឡើងវិញរបស់ខ្លួនផ្ទាល់ និងអ្វីដែលមាននៅក្នុងជំនួយស្មារតីបាន ការរំលឹកឡើងវិញបែបនេះ នឹងត្រូវបានអនុញ្ញាត៖

> *..សាក្សីម្នាក់អាចនឹងត្រូវបានអនុញ្ញាតឱ្យធ្វើការរំលឹកការចងចាំរបស់ខ្លួនឡើងវិញពីកំណត់ហេតុដែលបានធ្វើឡើងកាលពីពេលនោះបាន ...ប្រសិនបើអ្នកធ្វើកំណត់ហេតុ ឬជនម្នាក់ផ្សេងទៀតបានធ្វើកំណត់ហេតុនោះហើយ គាត់បានអានកំណត់ហេតុទាំងនោះទៅឃើញថា មានភាពស្របគ្នាជាមួយនឹងការនឹកឃើញឡើងវិញរបស់គាត់ជាបន្ទាប់មកទៀត...។ តាមយោបល់របស់ខ្ញុំ គឺមិនចាំបាច់ឱ្យការនឹកឃើញឡើងវិញ ហើយកំណត់ហេតុត្រូវគ្នាទាំងស្រុងនោះទេ។ បើសិនសាក្សីមានការចងចាំមួយចំនួនដាច់ដោយឡែកពីកំណត់ហេតុ បានអានកំណត់ហេតុទាំងនោះ ហើយបានទទួលស្គាល់ថាផ្នែកផ្សេងៗនៃកំណត់ហេតុត្រូវគ្នាជាមួយនឹងការចងចាំរបស់គាត់នោះថាជាការត្រឹមត្រូវមែននោះ ទើបគួរអនុញ្ញាតឱ្យសាក្សីនោះធ្វើការរំលឹកឡើងវិញនូវការចងចាំ ដោយប្រើកំណត់ហេតុទាំងនោះ នៅក្នុងឱកាសមួយជាក្រោយមកទៀតនៅក្នុងតុលាការបាន...*[20]។

១៥- នៅចំពោះមុខតុលាការ ICC កំណត់ហេតុសំរឹតសម្រាំង កំណត់ហេតុរបស់មន្ត្រីស៊ើបអង្កេត ឬឯកសារផ្សេងៗទៀតដែលមិនបង្ហាញឱ្យឃើញថាមានការទទួលយល់ព្រមរបស់សាក្សី លើភ័ស្តុតាងដែលមាននៅក្នុងនោះ ក៏ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យសម្រាប់គោលបំណងរំលឹកឡើងវិញនូវការចងចាំរបស់ខ្លួននោះទេ[21]។ ករណីលើកលែងមួយចំនួន ត្រូវបានគេធ្វើឡើងចំពោះចម្លើយសាក្សីទាំងឡាយណាដែលគ្មានចុះហត្ថលេខា នៅក្នុងករណីដែលសាក្សីបានឹយល់ព្រមយ៉ាងច្បាស់លាស់លើភ័ស្តុតាងដែលមាន

[20] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់ទំព័រទី ៥៩៣-៥៩៤។

[21] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06, ប្រតិចារិក, ចុះថ្ងៃទី ១៦ មករា ២០០៩ ត្រង់ទំព័រទី២៤-២៥។

នៅក្នុងនោះ និងលើឯកសារនានាដែលបានលើកយោងនៅក្នុងចម្លើយសាក្សីដែលភាគីអ្នកកោះហៅសាក្សីមានបំណងចង់ប្រើប្រាស់នៅក្នុងពេលសួរដេញដោល[22]។

១៦- គោលបំណងតែមួយគត់នៃការបង្ហាញឯកសារនានាជូនសាក្សីនៅក្នុងកាលៈទេសៈទាំងនេះគឺ ដើម្បីរំលឹកឡើងវិញនូវការចងចាំកាលពីមុន (គឺថា នៅក្នុងរង្វង់ការដឹងដោយផ្ទាល់របស់សាក្សី) ដែលអាច "កាន់តែភ្លេចអស់បន្តិចម្តងៗអាស្រ័យដោយពេលវេលាដែលចេះតែកន្លងទៅ"[23]។ សាក្សីទាំងឡាយរបស់អង្គជំនុំជម្រះមានកាតព្វកិច្ចត្រូវធ្វើសម្បថថា "និយាយតែការពិត" ទៅតាមអ្វីដែលពួកគេ "បានដឹង, បានឃើញ, បានឮ, និងបានចាំ" តែប៉ុណ្ណោះ[24]។ ដោយសារការធ្វើសវនាការនាពេលនេះដើម្បីធ្វើការសាកល្បងអំពីសច្ចសីលភាពនៃអង្គហេតុ បានកើតឡើងអស់ពេលជាងបីទសវត្សរ៍កន្លងមកហើយនោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការផ្តល់ឲ្យសាក្សីនូវមធ្យោបាយ និងឱកាសល្អ ដើម្បីធ្វើការរំលឹកឡើងវិញនូវការចងចាំរបស់ខ្លួនមុខ នឹងជួយផ្តល់លទ្ធភាពឲ្យពួកគេអាចគោរពតាមពាក្យសម្បថរបស់ខ្លួន និងធានាឲ្យប្រាកដថាភស្តុតាងដែលមានភវនីយភាពដ៏មានសក្តានុពល មិនមានការបាត់បង់។ ការអនុញ្ញាតក្នុងការប្រើប្រាស់នូវភស្តុតាងជាឯកសារទាំងនេះ នឹងជួយថែមទៀតដល់អង្គជំនុំជម្រះក្នុងការប្រកាន់ខ្ជាប់នូវមុខងារក្នុងការស្វែងរកការពិត ដោយមិនផ្តល់ភាពមិនត្រឹមត្រូវដល់ភាគីណាមួយឡើយ។

### *ការឆ្លើយថាភូតលើឯកសារដោយគ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង ឬការជួយដល់អង្គជំនុំជម្រះដើម្បីវាយតម្លៃអំពីទម្ងន់*

១៧- សាក្សីម្នាក់អាចមានលទ្ធភាពក្នុងការបញ្ជាក់ ឬបដិសេធមិនផ្តល់យថាភាព និងភាពអាចឲ្យជឿទុកចិត្តលើឯកសារបាន សូម្បីតែចំពោះឯកសារដែលខ្លួនមិនដែលធ្លាប់បានឃើញពីមុនមកក៏ដោយ -ការដឹងដោយផ្ទាល់យ៉ាងគ្រប់គ្រាន់ ដើម្បីទទួលស្គាល់ កំណត់អត្តសញ្ញាណ ឬដកចេញនូវលក្ខណៈ ពិសេសផ្សេងៗនៃឯកសារណាមួយ ដូចជា លក្ខណៈពិសេសនៃហត្ថលេខា សំណៅអក្សរសរសេរដៃ ឬរចនាសម្ព័ន្ធ ដូចជា ត្រា, លេខរបស់មន្ទីរ, លេខកូដ, ឬឈ្មោះហៅក្រៅដែលមាន លក្ខណៈ

[22] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់ទំព័រទី ២៥។

[23] ករណីរឿងក្តីរបស់ *R ទល់នឹង VanEindhoven*, សំណុំរឿងលេខ 2006 NUCJ 12 (តុលាការយុត្តិធម៌ទីក្រុង Nunavut នៃប្រទេសកាណាដា)។

[24] ក្រមនីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឧបសម្ព័ន្ធ។

ខុសៗគ្នា, ការប្រើពាក្យពេចន៍, អាសយដ្ឋាន, ឬហត្ថលេខារបស់អ្នកនិពន្ធឯកសារនោះ បើសិន សាក្សីទាំងនោះបែរទៅជាធ្លាប់បានស្គាល់ហត្ថលេខារបស់ជននោះយ៉ាងច្បាស់។

១៨- ការប្រើប្រាស់នូវភ័ស្តុតាងសក្ខីកម្ម ដើម្បីធ្វើយថាភូតលើឯកសារនានាដែលអាចមិនមែនជាឯកសារដែលត្រូវបានតែងនិពន្ធដោយសាក្សីខ្លួនឯងផ្ទាល់ គឺត្រូវបានគាំទ្រដោយទម្លាប់អនុវត្តដែលមានមកហើយរបស់តុលាការ *ពិសេសនានា* និងតុលាការ ICC។

១៩- នៅក្នុងករណីរឿងក្តីរបស់ *Delalić និងគូរកន* មេធាវីការពារក្តីបានតវ៉ាជំទាស់ចំពោះការប្រើប្រាស់ចម្លើយសាក្សីដើម្បីធ្វើយថាភូតលើឯកសារនានាដែលសាក្សីធ្លាប់បានគូសសញ្ញាជាសម្គាល់ នៅលើនោះកាលពីមុន (ទោះបីជាសាក្សីនោះក្រោយមកគាត់មិនកំណត់អត្តសញ្ញាណនៃសញ្ញាសំគាល់ណាមួយដែលនៅលើឯកសារទាំងនោះបានទៀតក៏ដោយ) ប៉ុន្តែឯកសារនោះត្រូវបានសរសេរដោយភាគីទីបី(តតីយភាគី) ដែលមិនមានវត្តមាននៅក្នុងពេលដំណើរការនៃការជំនុំជម្រះក្តីនោះ[25]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានរកឃើញថា គ្មានលក្ខខណ្ឌណាតម្រូវថា ឯកសារមួយត្រូវតែធ្វើយថាភូតដោយអ្នកដែលបានតែងនិពន្ធឯកសារនោះឡើយ ដរាបណានៅមានសល់សូចនាគ្រប់គ្រាន់ថាសាក្សីអាចមានលទ្ធភាពក្នុងការផ្តល់យថាភូតបាន[26]។ ទោះបីជាសាក្សីនោះគ្មានលទ្ធភាពអាចរកឃើញសញ្ញាជាសម្គាល់ណាមួយនៅលើឯកសារដែលបានបង្ហាញជូននោះក្តី ក៏អង្គជំនុំជម្រះបានរកឃើញថា សាក្សីនេះអាចឱ្យជឿទុកចិត្តបាន ដោយសារ ការដឹងរបស់គាត់អំពីថាតើឯកសារទាំងនេះត្រូវបានរក្សាទុកបែបដូចម្តេច[27]។

២០- នៅក្នុងករណីរឿងក្តីរបស់ *Lubanga Dyilo* មានសាក្សីម្នាក់បានមកចូលបង្ហាញខ្លួនដោយមានលិខិតមួយមកពីនាយកផ្នែកប្រវេសន៍ថ្នាក់ខេត្ត ដែលផ្ញើទៅឱ្យជនជាប់ចោទក្នុងឋានៈគាត់ជាប្រធាន*សម្ព័ន្ធភាពនៃអ្នកស្នេហាជាតិរបស់ប្រទេសកុងហ្គោ/ ការផ្សះផ្សា និងសន្តិភាព (Union des Patriotes*

---

[25] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Zejnil Delalić, *និងគូរកន, សំណុំរឿងលេខ* IT-96-21, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាដែលស្នើសុំឱ្យទទួលយកភ័ស្តុតាង ចុះថ្ងៃទី១៩ មករា ១៩៩៨, ត្រង់កថាខណ្ឌទី ១១។

[26] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់កថាខណ្ឌទី ២៥។

[27] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល*។

*Congolais/Reconciliation et Paix* (UPC/RP)[28]។ ទោះបីជា សាក្សីដែលកាលពីមុនធ្លាប់ត្រូវបានគេបង្ហាញលិខិតនេះ ហើយលិខិតនេះត្រូវបានគេដាក់បញ្ចូលជាផ្លូវការនៅក្នុងចម្លើយសាក្សី គាត់មិនមែនជាអ្នកនិពន្ធ ហើយក៏មិនមែនជាអ្នកទទួលលិខិតនេះដែរ ហើយក៏គ្មានភស្តុតាងត្រូវបានគេឲ្យដាក់នៅក្នុងចម្លើយសាក្សីរបស់គាត់ដោយផ្អែកលើលិខិតនេះដែរ[29]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC បានអនុញ្ញាតឲ្យសាក្សីពិគ្រោះយោបល់អំពីលិខិតនេះ ក្នុងគោលបំណងបង្កើតយថាភាពលើលិខិតនេះដោយផ្អែកលើព័ត៌មានដែលគាត់ធ្លាប់បានចូលរួមក្នុងនោះជាសម្ងាត់ នៅក្នុងមុខតំណែងរបស់គាត់ផ្ទាល់ ជាប្រភេទរួមមួយនៃឯកសារសម្រាប់រាយការណ៍នៅក្នុងUPC[30]។ អង្គជំនុំជម្រះបានអនុញ្ញាតបន្ថែមឲ្យសាក្សីផ្តល់ភស្តុតាងស្តីពីគោលបំណង និងនីតិវិធីនៃប្រព័ន្ធសម្រាប់រាយការណ៍ទៀតផង។

២១- ដោយយល់ឃើញអំពីទម្លាប់អនុវត្តដែលត្រូវបានបង្កើតឡើងដោយមានមូលដ្ឋានត្រឹមត្រូវ ស្តីពីការដាក់ឯកសារទៅឲ្យសាក្សីដើម្បីធ្វើយថាភូត និងផ្តល់ទម្ងន់ ដោយផ្អែកលើមូលដ្ឋាននៃការដឹងដោយផ្ទាល់របស់សាក្សីម្នាក់*អំពីចំណាត់ថ្នាក់នៃឯកសារនានា* ជាជាងឯកសារដែលផ្តល់ជូននោះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សាក្សីដែលធ្លាប់ដឹងអំពីទម្រង់ជាស្តង់ដានៃឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ដូចជា ឯកសារបោះពុម្ពផ្សាយនានា(ដែលក្នុងនោះរួមទាំងទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជន-យុវនារីផង) របាយការណ៍ផ្សេងៗ និងសារទូរលេខ គួរត្រូវបានអនុញ្ញាតឲ្យពិនិត្យឡើងវិញ និងធ្វើសក្ខីកម្មអំពីឯកសារទាំងនេះ ដោយមិនគិតថាតើពួកគេធ្លាប់បានឃើញ ឬមិនធ្លាប់បានឃើញឯកសារនោះឡើយ។ ទម្លាប់អនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃៗទៀតបង្ហាញឲ្យឃើញថាទំនាក់ទំនងគ្រប់គ្រាន់មួយនឹងមានអត្ថិភាពនៅចន្លោះរវាងឯកសារ និងការដឹងដោយផ្ទាល់របស់សាក្សី បើសិនជាទម្រង់ទូទៅនៃឯកសារអាចឲ្យសាក្សីស្គាល់បាន និងមានភាពស៊ីគ្នាជាមួយនឹងចំណាត់ថ្នាក់នៃឯកសារនានាដែលសាក្សីធ្លាប់បានឃើញពីមុនមក។

### *ការធ្វើឲ្យខ្លឹមសារនៃឯកសារនានាបញ្ជាក់ការពិតទៅវិញទៅមកដោយភាពស៊ីសង្វាក់គ្នា ឬការសន្និដ្ឋានសរុប ផ្អែកតាមខ្លឹមសារទាំងនោះ*

[28] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06-T-125,ប្រតិចារិក , ចុះថ្ងៃទី ១២ កុម្ភៈ ២០០៩, ត្រង់ទំព័រ ២៧។

[29] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់ទំព័រទី ២៨។

[30] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល* ត្រង់ទំព័រទី ២៩។

២២- សហព្រះរាជអាជ្ញារកឃើញការគាំទ្រនៅក្នុងនីតិវិធីរបស់ អវតក និងនៅក្នុងទម្លាប់អនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតដែលឲ្យសាក្សីធ្វើសក្ខីកម្មទាក់ទងនឹងឯកសារណាមួយដែលខ្លួនមិនដែលធ្លាប់បានឃើញពីមុនមក នៅពេលដែលសាក្សីនោះធ្លាប់បានដឹងដោយផ្ទាល់អំពីបុគ្គល ឬព្រឹត្តិការណ៍នានាដែលបានរៀបរាប់នៅក្នុងឯកសារនោះ។

២៣- ប្រភេទនៃការប្រើប្រាស់ឯកសារនេះដែលលេចឡើងនៅក្នុងសំណុំរឿង០០២/០១ ក្នុងបរិបទបញ្ជីឈ្មោះ និងកំណត់ហេតុអ្នកទោសនៅស-២១ ដែលសាក្សីឈ្មោះ ឌុច បានទទួលស្គាល់ទម្រង់ ទូទៅរបស់វានេះ ឌុច ត្រូវបានអនុញ្ញាតឲ្យពិនិត្យឡើងវិញនូវប្រភេទនៃឯកសារនានាដែលគាត់ធ្លាប់បានដឹង ស្ទម្បីតែគាត់មិនបានចងចាំថាពីមុនថាគាត់ធ្លាប់បានឃើញឯកសារជាក់លាក់នីមួយៗបែបនេះក៏ដោយ[31]។

២៤- នៅក្នុងករណី *Lubanga Dyilo* មានសាក្សីមួយរូបត្រូវបានគេបង្ហាញដោយរូបថតមួយសន្លឹក ដែលបានបោះផ្សាយនៅក្នុងសារព័ត៌មានមួយ[32]។ ទោះបីជាសាក្សីរូបនោះបានបញ្ជាក់ថាគាត់មិន ធ្លាប់បានឃើញរូបថតនោះពីមុនមកក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យមានការតាំងសំណួរទាក់ទងទៅនឹងអត្តសញ្ញាណរបស់បុគ្គលទាំងនោះ ដោយរួមទាំងជនជាប់ចោទផង ដែលពណ៌នានៅក្នុងរូបថតនោះ ព្រមទាំងពេលវេលានៃរូបថតនោះ ដោយមានមូលដ្ឋាននៅលើឯកសណ្ឋានដែលបុគ្គលទាំងនោះបានស្លៀកពាក់[33]។

២៥- នៅក្នុងករណី *Šešelj* មានសាក្សីមួយរូបត្រូវបានគេបង្ហាញដោយលិខិតមួយដែលបានចុះហត្ថលេខាក្នុងនាមស្នងការនគរបាលនៃប្រទេស Herzegovina ទាក់ទងទៅនឹងសកម្មភាពនានារបស់ក្រុមយោធាប្រតិព័ទ្ធដែលនៅក្រោមបញ្ជារបស់ជនជាប់ចោទ។ ទោះបីជាសាក្សីរូបនោះមិនធ្លាប់បានឃើញឯកសារនោះពីមុនមកក៏ដោយ ក៏គេបានអនុញ្ញាតឲ្យគាត់ផ្ដល់សក្ខីកម្មស្ដីពីខ្លឹមសារនៃឯកសារនោះដែរ ដោយ

[31] **E1/56.1** ប្រតិចារឹកកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី២៩ មីនា ២០១២ (សវនាការថ្ងៃទី៤៤) ត្រង់ទំព័រទី ៧២-៧៥។

[32] *រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06-T-343, ប្រតិចារឹកសវនាការ, តុលាការព្រហ្មទណ្ឌអន្តរជាតិ, ថ្ងៃទី៤ មេសា ២០១១ ត្រង់ទំព័រទី១៤។

[33] *ដដែលដូចមុន* ត្រង់ទំព័រទី១៤-១៦។

អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា សក្ខីកម្មរបស់គាត់ដូចនេះបានយោងទៅដល់សាច់រឿងមួយចំនួនដែលបានពោលនៅក្នុងឯកសារនោះ[34]។

២៦- នៅក្នុងករណី *Krajišnik* មានសាក្សីមួយរូបត្រូវបានគេអនុញ្ញាតឲ្យអាន និងឲ្យធ្វើអត្ថាធិប្បាយលើប្រិចារឹកមួយនៃសម័យប្រជុំសភាជាតិនៃប្រទេស Republika Srpska[35]។ ទោះបីជាសាក្សីរូបនោះមិនមានវត្តមាននៅក្នុងសភា និងមិនធ្លាប់បានឃើញប្រិចារឹកនោះពីមុនមកក៏ដោយ ក៏គាត់ធ្លាប់បានដឹងពីទស្សនៈផ្សេងៗរបស់ជនជាប់ចោទស្តីពីសាច់រឿងជាក់លាក់មួយចំនួន និងត្រូវបានគេយកទៅផ្ទៀងផ្ទាត់ជាមួយនឹងផ្នែកនានានៃប្រតិចារឹកនោះ ដើម្បីបញ្ជាក់ថាសេចក្តីថ្លែងរបស់ជនជាប់ចោទ ស៊ីគ្នាទៅនឹងគោលជំហរនានាដែលជនជាប់ចោទធ្លាប់បានប្រកាន់យក នៅក្នុងអម្លុងពេលនៃកិច្ចដំណើរការចរចារកសន្តិភាព[36]។

២៧- នៅក្នុងករណី *Stanišič* មានសាក្សីមួយរូប ត្រូវបានគេបង្ហាញដោយឯកសារមួយដែលមានគោលការណ៍ណែនាំចេញដោយអគ្គសេនាធិការកំពូលនៃការិយាល័យអយ្យការយោធា ហើយសាក្សីរូបនោះបានសារភាពថាពុំធ្លាប់បានឃើញឯកសារនោះពីមុនមកទេ ក៏ប៉ុន្តែខ្លួនបានដឹងពីគោលការណ៍ទូទៅនានានៅក្នុងឯកសារនោះ[37]។ គេបានអនុញ្ញាតឲ្យសាក្សីរូបនោះផ្តល់សក្ខីកម្មអំពីគោលការណ៍នៅក្នុងឯកសារនោះ ពីព្រោះសាក្សីរូបនោះធ្លាប់ធ្វើជាមេបញ្ជាការយោធា ដែលខ្លួនគាត់ផ្ទាល់បានអះអាងថាគាត់ធ្លាប់បានដឹងអំពីគោលការណ៍ទាំងនោះ[38]។

---

[34] *រដ្ឋអាជ្ញា ទល់នឹង Vojislav Seselj*, សំណុំរឿងលេខ IT-03-67-T, ប្រតិចារឹក, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី២ កុម្ភៈ ២០១០ ត្រង់ទំព័រទី ១៥៣៣២-៣៤។ *សូមអានផងដែរ រដ្ឋអាជ្ញា ទល់នឹង Vojislav Seselj*, សេចក្តីសម្រេចលើសំណើសុំឲ្យទទួលយកឯកសារដែលដាក់បង្ហាញតាមរយៈសាក្សីឈ្មោះ Visnja Bilic ធ្វើជាភ័ស្តុតាង, VS-1067 និង Vojislav Dabic, សំណុំរឿងលេខ IT-03-67-T, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី១៣ ធ្នូ ២០១០ ត្រង់កថាខណ្ឌទី ២៧-២៨។ [សក្ខីកម្មរបស់សាក្សីដែលបាននិយាយពីភាពពាក់ព័ន្ធ, ភាពគួរឲ្យជឿបាន និង តម្លៃជាភស្តុតាងនៃឯកសារ]។

[35] *រដ្ឋអាជ្ញា ទល់នឹង Momcilo Krajišnik*, សំណុំរឿងលេខ IT-00-39-T, ប្រតិចារឹក, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី២៤ មិថុនា ២០០៤ ត្រង់ទំព័រទី ៤២៩២-៤២៩៣។

[36] *ដដែលដូចមុន*។

[37] *រដ្ឋអាជ្ញា ទល់នឹង Mićo Stanišić* និង *Stojan Zupljanin*, សំណុំរឿងលេខ IT-08-91-T, ប្រតិចារឹក, អង្គជំនុំជម្រះ សាលាដំបូង ICTY, ថ្ងៃទី២ មីនា ២០១២ ត្រង់ទំព័រទី ២៦៩៩២-៩៣។

[38] *ដដែលដូចមុន*, ត្រង់ទំព័រទី ២៦៩៩៤-៩៥។

២៨- នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា មានស៊ីណារីយ៉ូស្រដៀងគ្នានេះជាច្រើនដែលអង្គជំនុំជម្រះអាចរកឃើញថាមានចំណងទាក់ទងគ្នាគ្រប់គ្រាន់រវាងឯកសារមួយ និងការដឹងឮ ដោយផ្ទាល់របស់សាក្សីម្នាក់ ហើយអនុញ្ញាតឲ្យសក្ខីកម្មនេះ បញ្ជាក់បន្ថែមសេចក្តី ឬសរុបសេចក្តីចេញពីខ្លឹមសារនៃឯកសារនោះ។ ឧទាហរណ៍ សាក្សីមួយរូបអាចធ្លាប់បានចូលរួមនៅក្នុងការប្រជុំមួយ ប៉ុន្តែមិនដែលបានឃើញកំណត់ហេតុ ឬកំណត់ត្រា ដែលគេបានរៀបចំសម្រាប់ធ្វើការប្រជុំនោះទេ។ នៅក្នុងកាលៈទេសៈបែបដូច្នេះ ដោយសារតែការដឹងឮផ្ទាល់របស់សាក្សីរូបនោះ មានទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលបានរៀបរាប់នៅក្នុងឯកសារនោះ គេត្រូវអនុញ្ញាតឲ្យសាក្សីរូបនោះបញ្ចេញទស្សនៈ និងពន្យល់ពីឯកសារនោះ និងភាពពិតប្រាកដរបស់ឯកសារនោះទាក់ទងទៅនឹងព្រឹត្តិការណ៍នោះ។ ស្រដៀងគ្នានេះដែរ សាក្សីមួយរូបអាចធ្លាប់បានឮពីបទឧទ្ទេសនាមមួយថ្លែងដោយបុគ្គល ឬតាមការផ្សាយវិទ្យុនៅពេលដែលគេបានថ្លែងឧទ្ទេសនាម ក៏ប៉ុន្តែពីមុនមកគាត់ពុំធ្លាប់បានឃើញការបោះពុម្ពផ្សាយបទឧទ្ទេសនាមនោះជាលាយលក្ខអក្សរ ឬជាប្រតិចារឹកនៃការផ្សាយបទឧទ្ទេសនាមតាមវិទ្យុនោះទេ។ នៅក្នុងកាលៈទេសៈនោះ ដោយសារតែការដឹងឮផ្ទាល់របស់សាក្សីស្តីពីព្រឹត្តិការណ៍លើកឡើងខាងដើមនេះ គេត្រូវអនុញ្ញាតឲ្យសាក្សីរូបនោះធ្វើការពិនិត្យឯកសារឡើងវិញ និងបញ្ជាក់ថាតើបទឧទ្ទេសនាមដែលសាក្សីរូបនោះធ្លាប់បានឃើញ ឬធ្លាប់បានឮ ដែរ ឬអត់។ ក្នុងរបៀបនេះ អង្គជំនុំជម្រះនឹងឋិតនៅក្នុងគោលជំហរមួយដ៏ប្រសើរ ដើម្បីធ្វើការវាយតម្លៃពីសច្ចសីលភាព ទាំងលើឯកសារ និងទាំងលើភ័ស្តុតាងជាសក្ខីកម្ម។ ជាឧទាហរណ៍មួយបន្ថែមទៀត សាក្សីមួយរូបអាចនឹងមានការដឹងឮដោយផ្ទាល់ពីការចាប់ខ្លួនបុគ្គលណាម្នាក់ ដោយមិនអាចមានលទ្ធភាពចាំបាននូវកាលបរិច្ឆេទនៃការចាប់ខ្លួន ឬវាសនារបស់បុគ្គលនោះឡើយ។ សាក្សីរូបនេះអាចត្រូវបានបង្ហាញនូវបញ្ជីឈ្មោះអ្នកទោសនៅស-២១ ឬទំព័រដើមនៃចម្លើយសារភាព អ្នកទោសនៅស-២១ ជាតួយ៉ាង ដើម្បីបញ្ជាក់សេចក្តីបន្ថែមទៅលើអង្គហេតុនៃការចាប់ខ្លួន ហើយការបញ្ជូនខ្លួនទៅកាន់មន្ទីរស-២១ នៃបុគ្គលតែមួយ។

២៩- លើសពីនេះ នៅក្នុងករណីដែលសាក្សីឋិតនៅក្នុងតំណែងទទួលខុសត្រូវនៅក្នុង បកក ឬនៅក្នុងរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ គេត្រូវអនុញ្ញាតឲ្យភាគីនានាធ្វើការបង្ហាញដល់សាក្សីរូបនោះ នូវឯកសារសហកាលនានាដែលឆ្លុះបញ្ចាំងពីការបង្កើតគោលនយោបាយផ្សេងៗ ហើយសួរដល់សាក្សីរូបនោះថាតើគោលនយោបាយនានាដែលមាននៅក្នុងឯកសារនោះ តាមពិត ត្រូវបានគេអនុវត្ត- ឬមួយក៏មិនបានអនុវត្តទេ - នៅក្នុងអង្គការតាមកម្រិតទទួលខុសត្រូវរបស់ពួកគាត់។ នៅក្នុងករណី *Lubanga Dyilo* មានសាក្សីមួយរូបត្រូវបានគេបង្ហាញដោយឯកសារមួយដែលបានបញ្ជាឲ្យមានការ

ចែកចាយក្រឹត្យរបស់ប្រធាន[39]។ ដោយធ្លាប់ត្រូវបានគេបានបង្ហាញក្រឹត្យនោះផ្ទាល់ និងដោយបានបញ្ជាក់ថាគាត់បានជួយនៅក្នុងការព្រាងក្រឹត្យនោះ[40] សាក្សីរូបនោះបានផ្តល់សក្ខីកម្មថា គាត់មិនបានចងចាំថាបានអានបញ្ហានោះទេ ក៏ប៉ុន្តែបានដឹងថាបុគ្គលណាខ្លះបានចុះហត្ថលេខា[41]។ សាក្សីរូបនោះមានលទ្ធភាពអាចផ្តល់សក្ខីកម្មបានពីការអនុវត្តធម្មតាសម្រាប់ក្រឹត្យស្រដៀងគ្នានេះ និងថាតើតាមការដឹងឮរបស់គាត់ ក្រឹត្យនេះត្រូវបានគេអនុវត្ត ឬមួយក៏អត់[42]។ ទោះបីជាសំណួរបែបដូច្នេះត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរក៏ដោយ ក៏ឯកសារនេះផ្ទាល់មិនត្រូវបានដាក់ចូលធ្វើជាភស្តុតាងតាមរយៈសាក្សីរូបនេះឡើយ ព្រោះថាសក្ខីកម្មរបស់សាក្សីរូបនេះមានមូលដ្ឋាននៅលើការដឹងឮផ្ទាល់របស់គាត់ដែលទាក់ទងទៅនឹងបទបញ្ជាស្រដៀងគ្នាផ្សេងៗ និងមិនមែននៅលើការដឹងឮជាក់លាក់ដែលទាក់ទងទៅនឹងឯកសារដែលបានដាក់បង្ហាញនោះទេ[43]។

*ការសាកល្បងទៅលើភាពគួរឲ្យជឿបានរបស់សាក្សី*

៣០- តាមរយៈសេចក្តីណែនាំចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២[44] អង្គជំនុំជម្រះបានរក្សាទុកគោលការណ៍ទូទៅដែលថាភស្តុតាងជាឯកសារអាចនឹងត្រូវទទួលយកបានក្នុងគោលបំណងធ្វើការសាកល្បងទៅលើភាពគួរឲ្យជឿជាក់បានរបស់សាក្សី។ ទោះបីជាអង្គជំនុំជម្រះកត់សម្គាល់ថា ភស្តុតាងបែបដូច្នេះត្រូវតែភ្ជាប់ទៅនឹងបទដ្ឋានធម្មតាសម្រាប់ភស្តុតាងដែលអាចទទួលយកបានផ្សេងទៀតក៏ដោយ សេចក្តីណែនាំនេះមិនបាននិយាយឲ្យបានច្បាស់លាស់ទេអំពីភាពគ្រប់គ្រាន់នៃទំនាក់ទំនងដែលបានតម្រូវឲ្យមានរវាងឯកសារ និងសាក្សី ដើម្បីធានាពីភាពអាចទទួលយកបាន។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថាឲ្យតែមានចំណងទាក់ទងគ្នាគ្រប់គ្រាន់រវាងឯកសារ និងការដឹងឮផ្ទាល់របស់សាក្សី ឯកសារណាមួយក៏ដោយ - រួមទាំងឯកសារដែលសាក្សីរូបនោះមិនធ្លាប់បានឃើញពីមុនមកក៏ដោយ - អាចនឹងត្រូវបាន

---

39 *រដ្ឋអាជ្ញា ទល់នឹង Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06, ប្រតិចារឹកសវនាការ, តុលាការព្រហ្មទណ្ឌអន្តរជាតិ, អង្គជំនុំជម្រះ សាលាដំបូង ICTY, ថ្ងៃទី៨ មេសា ២០១១ ត្រង់ទំព័រទី ១៨។

40 *ដដែលដូចមុន,* ត្រង់ទំព័រទី ១៥-១៦។

41 *ដដែលដូចមុន,* ត្រង់ទំព័រទី ១៨។

42 *ដដែលដូចមុន,* ត្រង់ទំព័រទី ១៨-២០។

43 *ដដែលដូចមុន,* ត្រង់ទំព័រទី ២១-២៥។

44 **E199** អនុស្សរណៈផ្ញើជូនទៅកាន់ភាគីនានា, សេចក្តីណែនាំពាក់ព័ន្ធនឹងឯកសារដែលភាគីស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះសម្រាប់គោលបំណងនៃការសួរផ្ទាល់, ថ្ងៃទី២៤ ឧសភា ២០១២។

ដាក់ជូនសាក្សីក្នុងគោលបំណងជួយដល់អង្គជំនុំជម្រះ នៅក្នុងការវាយតម្លៃទៅលើភាពគួរឲ្យជឿបានរបស់សាក្សីនោះ។

៣១- នៅក្នុងករណី *Karadžić* អង្គជំនុំជម្រះសាលាដំបូង ICTY បានតម្កល់ទុកគោលការណ៍ជាទូទៅស្រដៀងគ្នាមួយដូចអង្គជុំនុំជម្រះនេះដែរ ដោយបានយល់ឃើញថា គេមិនត្រូវទទួលយកឯកសារទាំងនោះតាមរយៈសាក្សីបានឡើយ បើសាក្សីមួយរូបនោះមិនបានដឹងឮពីឯកសារនោះទេ[45]។ យ៉ាងណាក៏ដោយ ករណីលើកលែងមួយត្រូវបានគេទទួលស្គាល់ ក្នុងគោលបំណងធ្វើការសាកល្បងលើភាពគួរឲ្យជឿបានរបស់សាក្សី៖

> *គោលការណ៍ទូទៅនេះ មិនបដិសេធលទ្ធភាពនៃការទទួលយកនូវឯកសារដែលត្រូវប្រឈមនឹងភាពគួរឲ្យជឿបានរបស់សាក្សី រួមទាំង នៅក្នុងស្ថានភាពនានាដែលសាក្សីរូបនោះថ្លែងថាគាត់មិនការដឹងឮពីឯកសារនោះ ឬក៏បដិសេធខ្លឹមសាររបស់ឯកសារនោះផង។ នៅក្នុងបរិបទនេះ អង្គហេតុពិតដែលថាឯកសារនោះត្រូវមានពីភាពគួរឲ្យជឿបានរបស់សាក្សី អាចនឹងបង្កើតបានជាចំណងទាក់ទងគ្នាមួយយ៉ាងគ្រប់គ្រាន់រវាងសាក្សីរូបនោះ និងឯកសារដែលនឹងត្រូវបានគេទទួលយក។ យ៉ាងណាក៏ដោយ ភាគីដែលត្រូវបង្ហាញឯកសារ ត្រូវតែអាចមានលទ្ធភាពធ្វើឲ្យអង្គជំនុំជម្រះយល់បានពីយថាភាព និងភាពទុកចិត្តបាននៃឯកសារនោះផងដែរ មុននឹងត្រូវបានសម្រេចថាទទួលយក*[46] *។*

៣២- គេអាចធ្វើការសាកល្បងអំពីភាពគួរឲ្យជឿបានរបស់សាក្សី ដោយឲ្យភាគីមួយចង្អុលបង្ហាញពីសេចក្តីថ្លែងពីមុនរបស់សាក្សី ឬឯកសារដទៃផ្សេងទៀត រួមទាំង ឯកសារដែលសាក្សីរូបនោះមិនធ្លាប់បានឃើញពីមុនមកផង ហើយផ្តល់ឱកាសឲ្យសាក្សីរូបនោះធ្វើការពន្យល់ពីភាពមិនរលូនគ្នាផ្សេងៗដែលបានចោទប្រកាន់។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង ICTY បានកត់សម្គាល់ នៅក្នុងករណី *Popović* ថា៖

---

[45] *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić*, សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការទទួលយកឯកសារតាមរយៈសាក្សី, សំណុំរឿងលេខ IT-95-5118-T, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី១៩ ឧសភា ២០១០ ត្រង់កថាខណ្ឌទី ១០ (ការលើកឡើងផ្ទៃក្នុងត្រូវបានលុបចោល)។

[46] *ដដែលដូចមុន,* ត្រង់ទំព័រទី ១១។

> *ដូចដែលអង្គហេតុពិតដែលថា នៅក្នុងកាលៈទេសៈមួយចំនួន សាក្សីបានអះអាងថាខ្លួនមិនមានការដឹងឮអំពីឯកសារជាក់លាក់ទាំងនោះទេ ឬសូម្បីតែនៅក្នុងករណីមួយចំនួនដែលបញ្ហានានាត្រូវបានរៀបរាប់នៅក្នុងនោះក៏ដោយ យើងជឿជាក់ថា ជាគោលការណ៍ទូទៅកិច្ចនេះមិនបានច្រានចោលជាមុននូវការទទួលយកឯកសារបែបដូច្នោះឡើយ។ នៅតែមានភាពទាក់ទងគ្នានៅឡើយសម្រាប់ធ្វើការវាយតម្លៃពីភាពគួរឲ្យជឿបានរបស់សាក្សីរូបនោះ ឬពីគោលបំណងដទៃទៀត*[47] ។

៣៣- ដូចជាអង្គជំនុំជម្រះសាលាដំបូង អវតក ដែរ[48] អង្គជំនុំជម្រះសាលាដំបូង ICTR បានទទួលយកសេចក្តីថ្លែងនានារបស់បុគ្គលដែលមិនត្រូវផ្តល់សក្ខីកម្ម យកមកប្រើប្រាស់នៅក្នុងអំឡុងពេលសួរដេញដោលសាក្សីដោយភាគីដទៃ ឲ្យតែសេចក្តីថ្លែងទាំងនោះមានលក្ខណៈ “ចាំបាច់សម្រាប់ធ្វើការវាយតម្លៃរបស់អង្គជំនុំជម្រះទៅលើភាពគួរឲ្យជឿបានរបស់សាក្សី តែគេមិនប្រើប្រាស់សម្រាប់បង្ហាញការពិតនៃខ្លឹមសាររបស់សេចក្តីថ្លែងទាំងនោះឡើយ”[49]។ តុលាការ ICTY បានពន្លាតបទដ្ឋាននេះនៅក្នុងករណី *Karadžić* ដោយបានអនុញ្ញាតឲ្យយកសេចក្តីថ្លែងនានារបស់បុគ្គលដែលត្រូវផ្តល់សក្ខីកម្ម នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន[50]។

---

[47] *រដ្ឋអាជ្ញា ទល់នឹង Vujadin Popović* និងគូកន, សំណុំរឿងលេខ IT-05-88, ប្រតិចារឹក, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី៧ កញ្ញា ២០០៧ ត្រង់ទំព័រទី ១៥៤៥៩ បន្ទាត់ទី៧-១៥។

[48] **E1/73.1** ប្រតិចារឹកកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី១៧ ឧសភា ២០១២ (សវនាការថ្ងៃទី៦១) ត្រង់ទំព័រទី ៧៦។

[49] *រដ្ឋអាជ្ញា ទល់នឹង Aloys Simba*, សំណុំរឿងលេខ ICTR-01-76-A, *សាលដីកា* (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR), ថ្ងៃទី២៨ វិច្ឆិកា ២០០៧ ត្រង់កថាខណ្ឌទី ២០។.

[50] *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić*, សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការទទួលយកឯកសារតាមរយៈសាក្សី, សំណុំរឿងលេខ IT-95-5118-T, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី១៩ ឧសភា ២០១០ ត្រង់កថាខណ្ឌទី ២៥.ង៖ “ភាគីនានាអាចតាំងសំណួរដេញដោលសាក្សី (“សាក្សី ក”) នៅក្នុងតុលាការ ដោយប្រើសេចក្តីថ្លែងរបស់សាក្សីរូបនោះ ឬ ដោយប្រតិចារឹកនៃសក្ខីកម្មពីមុនរបស់សាក្សីម្នាក់ផ្សេងទៀត (“សាក្សី ខ”) ដែលបានមកពីសំណុំរឿងផ្សេងដែលនៅចំពោះមុខតុលាការនោះ។ បើសាក្សី ក បដិសេធលើខ្លឹមសារនៃភ័ស្តុតាងដែលបានដាក់នៅចំពោះមុខខ្លួននោះ ឬក៏ប្រកែកទៅនឹងភ័ស្តុតាងនោះៗ សេចក្តីថ្លែង ឬប្រតិចារឹកនៃសក្ខីកម្មពីមុនរបស់សាក្សី ខ នឹងពុំត្រូវបានទទួលយកឡើយ លើកលែងតែ និង រហូតទាល់តែគេបាននាំសាក្សី ខ ឲ្យចូលមកផ្តល់ភ័ស្តុតាងនៅក្នុងករណីនោះ។ បើសាក្សី ក អះអាង ឬ ទទួលយកខ្លឹមសារនៃភ័ស្តុតាងរបស់សាក្សី ខ ដែលបានដាក់នៅចំពោះមុខខ្លួននោះ ដូច្នោះផ្នែកនៃភ័ស្តុតាងរបស់សាក្សី ខ អាចត្រូវបានគេទទួលយក មិនចាំបាច់ថាតើសាក្សី ខ បានមកផ្តល់សក្ខីកម្ម ឬ មិនមកនោះទេ”។

៣៤- តុលាការ ICTY ក៏បានបញ្ជាក់ផងដែរថា ការអនុវត្តស្តីពីការទទួលយកភ័ស្តុតាងជាឯកសារ ដើម្បីធ្វើការសាកល្បងលើភាពឲ្យជឿបានរបស់សាក្សី បម្រើដល់បេសកកម្មនៃការស្វែងរកការពិតរបស់តុលាការនានា៖

> *ការសួរតទល់សាក្សីម្នាក់ ទៅលើឯកសាររបស់គាត់ដែលជាសង្កាត់ៗនៃសេចក្តីថ្លែងពីមុនៗរបស់គាត់ គឺអនុញ្ញាតឲ្យសាក្សីរូបនោះបានធ្វើការពន្យល់ បានធ្វើអត្ថាធិប្បាយ ឬបានបំភ្លឺ ទៅលើអត្ថិភាពនៃភាពមិនស្របគ្នាទាំងឡាយដែលបានចោទប្រកាន់ ដូច្នេះហើយ ឯករាជ្យភាពរបស់សាក្សីរូបនោះ គឺត្រូវបានគេគោរព និងបានធ្វើឲ្យភាពដែលអាចទុកចិត្តបាននៃសក្ខីកម្មកាន់តែប្រសើរឡើង*[51] ។

## IV. សំណើ

៣៥- ការប្រើប្រាស់ឯកសារដែលបានសង្ខេបនៅក្នុងផ្នែក III មិនមានបំណងធ្វើជាលក្ខណៈល្អិតល្អន់នោះទេ ប៉ុន្តែផ្ទុយទៅវិញ ដើម្បីបង្ហាញអំពីវិធីនានាដែលគេរំពឹងទុកដែលភាពគ្រប់គ្រាន់នៃចំណងទាក់ទងរវាងឯកសារមួយ និងការដឹងឮផ្ទាល់របស់សាក្សីណាម្នាក់ អាចធ្វើយុត្តិកម្មលើការប្រើប្រាស់ឯកសារនោះបាន - សូម្បីតែពីមុនមកមិនត្រូវបានសាក្សីរូបនោះ ធ្លាប់បានឃើញក៏ដោយ - ដោយមិនបានផ្តល់នូវភាពមិនត្រឹមត្រូវចំពោះភាគីណាមួយឡើយ និងស្របទៅតាមការស្វែងរកនូវការពិត។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ការប្រើប្រាស់នូវឯកសារទាំងបួនសម្រាប់សវនាការ ដែលមានចែងខាងលើនេះ ត្រូវគ្នាទៅនឹងគោលបំណងនៃការសម្រេចពីមុនៗលើបញ្ហានេះរបស់អង្គជំនុំជម្រះសាលាដំបូង គឺមានលក្ខណៈស្របគ្នាទៅនឹងវិធាន និងការអនុវត្តនានារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ហើយត្រូវបានអនុញ្ញាតឲ្យទទួលយក នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១។

---

[51] *រដ្ឋអាជ្ញា ទល់នឹង Halilovic*, សំណុំរឿងលេខ IT-01/48-T, សេចក្តីសម្រេចស្តីពីការទទួលយកសេចក្តីថ្លែងពីមុនរបស់សាក្សី មកធ្វើជាភ័ស្តុតាង, អង្គជំនុំជម្រះសាលាដំបូង ICTY, ថ្ងៃទី៥ កក្កដា ២០០៥ ត្រង់ទំព័រទី ៣។

៣៦- អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ ថាភាគីអាចប្រើប្រាស់ឯកសារសម្រាប់សវនាការជាមួយនឹងសាក្សីនានា សម្រាប់គោលបំណង៖

(ក) រំលឹកការចងចាំរបស់សាក្សី,

(ខ) ឆ្លើយថាភាពលើឯកសារផ្តល់ជូនណាមួយដែលបាន *ឃើញតែមួយក្រឡេកភ្នែក,* ឬដើម្បីជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃពីទម្ងន់ ដែលជាចុងបញ្ចប់ អាចយកចេញពីឯកសារនោះ,

(គ) បញ្ជាក់បន្ថែមសេចក្តីទៅលើខ្លឹមសារ ឬសេចក្តីសរុបអំពីខ្លឹមសារនៃឯកសារនោះ ដោយមានមូលដ្ឋាននៅលើការដឹងឮផ្ទាល់របស់សាក្សី, និង

(ឃ) ធ្វើការសាកល្បងទៅលើភាពគួរឲ្យជឿបានរបស់សាក្សី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |